# ពុទ្ធិកសមាគមវត្តខ្មែរម៉ូដេសតូ

MODESTO CAMBODIAN BUDDHIST SOCIETY, INC.

1528/1538 Grimes Avenue, Modesto, California 95358

Phone: (209) 522-3138


## បុណ្យពុទ្ធាភិសេក និងឆ្លងសមិទ្ធផលផ្សេងៗ

យើងខ្ញុំទាំងអស់គ្នាជាព្រះសង្ឃ អាចារ្យ គណៈកម្មការនិងពុទ្ធបរិស័ទចំណុះជើងវត្តខ្មែរម៉ូដេសតូទាំងមូល បានមូលមតិគ្នាជាឯកច្ឆ័ន្ទប្រារព្ធធ្វើបុណ្យពុទ្ធាភិសេកព្រះពុទ្ធបដិមាព្រះអង្គប្រទានពរកំពស់៤ម៉ែត្រ,ព្រះអង្គផ្ចាញ់មារ,ព្រះអង្គទ្រង់ឱ្យអភ័យទាន ព្រះអង្គសិវលី រូបសំណាកព្រះភិក្ខុអាចារ្យហែម ចៀវ រូបសំណាកព្រះបាទជ័យវរ្ម័នទី៧,ព្រះនាងឥន្ទ្រទេវីរូបសំណាកលោកឧកញ៉ា សឹង កុយ និងសម្ពោធចំណតរថយន្ត និងផ្លូវថ្នល់ដែលជាសទ្ធាជ្រះថ្លាដ៏ថ្លៃថ្លារបស់គ្រួសារអ្នកស្រី លឹម លីណា និងសប្បុរសជនយើងទាំងអស់។

អាស្រ័យហេតុនេះ អាត្មាភាព យើងខ្ញុំសូមនិមន្តព្រះតេជគុណគ្រប់ព្រះអង្គនិងគោរពអញ្ជើញ លោកយាយលោកតា អស់លោក លោកស្រី អ្នកនាងកញ្ញា និងពុទ្ធបរិស័ទជិតឆ្ងាយ ព្រមទាំងសប្បុរសជនប្រុសស្រីទាំងអស់មេត្តាចូលរួមក្នុងកម្មវិធីបុណ្យនេះឲ្យបានច្រើនកុះករនិងអនុមោទនាយកកុសលផលបុណ្យតាមកម្លាំងសទ្ធាជ្រះថ្លារៀងៗខ្លួន។

### កម្មវិធីបុណ្យ

ថ្ងៃសុក្រ៩កើត ខែពិសាខឆ្នាំរោងឆស័ក ព-ស ២៥៦៨ ត្រូវនឹងថ្ងៃទី៣១ ឧសភា ឆ្នាំ២០២៤ វេលាម៉ោង៥ល្ងាចជួបជុំព្រះសង្ឃនិងពុទ្ធបរិស័ទជិតឆ្ងាយនៅវត្តខ្មែរម៉ូដេសតូ ធ្វើបទនមស្សការព្រះរតនត្រ័យ សមាទានសីល និមន្តព្រះសង្ឃសូត្រពុទ្ធាភិសេក រួចនិមន្តព្រះតេជគុណមហាយិន នឿន សម្តែងព្រះធម៌ទេសនា លុះព្រឹកឡើងថ្ងៃសៅរ៍ទី១ខែមិថុនាឆ្នាំ២០២៤ម៉ោង១០និមន្តព្រះសង្ឃចំនួន២៥អង្គនិមន្តគោចរបិណ្ឌបាត ម៉ោង១០:៣០ ធ្វើបទនមស្សការព្រះរតនត្រ័យ សមាទានសីលនិងនិមន្ត ព្រះតេជគុណ ស្រួយ ហាញ សម្តែងព្រះធម៌ទេសនា ម៉ោង១១ វេរភត្តប្រគេនដល់ព្រះសង្ឃ និងល្ងាចម៉ោង៥ជួបជុំព្រះសង្ឃនិងពុទ្ធបរិស័ទជិតឆ្ងាយធ្វើបទនមស្សការព្រះរតនត្រ័យសមាទានសីលនិមន្តព្រះសង្ឃសូត្រពុទ្ធាភិសេករួចនិមន្តព្រះតេជគុណស្វាយ រិទ្ធីសម្តែងព្រះធម៌ទេសនា លុះព្រឹកឡើងថ្ងៃអាទិត្យទី២ខែឆ្នាំដដែលម៉ោង៩.៣០ រៀបចំសម្ពោធកាត់ខ្សែបូរដើម្បីប្រើប្រាស់ជាផ្លូវការនូវចំណតរថយន្តនិងផ្លូវថ្នល់ ម៉ោង១០.៣០នាទីនិមន្តព្រះសង្ឃ២៥អង្គនិមន្តគោចរបិណ្ឌបាត ម៉ោង១០.៥៥ ធ្វើបទនមស្សការព្រះរតនត្រ័យ សមាទានសីលនិងនិមន្ត ព្រះតេជគុណ គង់ ទិត សម្តែងព្រះធម៌ទេសនា ម៉ោង១១.២០នាទី វេរភត្តប្រគេនដល់ព្រះសង្ឃរួចនិមន្តព្រះសង្ឃសូត្រពហូទេវាជាកិច្ចបញ្ចប់បុណ្យ។

ធ្វើនៅវត្តខ្មែរម៉ូដេសតូ ថ្ងៃទី១១ខែមេសាឆ្នាំ២០២៤

| ចៅអធិការ | អាចារ្យសម្រាប់វត្ត | ប្រធានគណៈកម្មការនាយក |
|---|---|---|
| ភិក្ខុ យិន សួង | ស៊ុន សុផន | វ៉ាន់ ព្រំ |